# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Oct-2019, 15:07
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ សាធារណៈ/Public

ស្ថានភាពនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

## សំណើនានាពាក់ព័ន្ធនឹងចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន

---

ដាក់ដោយ៖

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Megan HIRST

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គឹម ម៉េងឃី

ឡោ ជុនធី

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

**ចៅក្រម គង់ ស្រីម ប្រធាន**

**ចៅក្រម Chandra Nihal JAYASINGHE**

**ចៅក្រម សោម សិរីវឌ្ឍ**

**ចៅក្រម Florence Ndepele MWACHANDE-MUMBA**

**ចៅក្រម ម៉ុង មុន្នីចរិយា**

**ចៅក្រម Maureen Harding CLARK**

**ចៅក្រម យ៉ា ណារិន**

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីណា

Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang LIU
Daniel LOSQ
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Mahesh RAI

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda J. HOLLIS

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្ដីជនជាប់ចោទ៖**

លោក គង់ សំអុន

Anta GUISSÉ

# I. សេចក្តីផ្តើម

១. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសង្ខេបនៃសាលក្រមរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០២ នៅឯសវនាការជាសាធារណៈ[១]។ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ភាគីបានទទួលការជូនដំណឹងអំពីសាលក្រមដែលមានសំអាងហេតុពេញលេញជាភាសាខ្មែរ អង់គ្លេស និងបារាំង[២]។ ក្រោយពីមានសំណើពី ខៀវ សំផន និង នួន ជា អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យភាគីដាក់សេចក្តីជូនដំណឹងទាំងអស់ត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩[៣]។ ការិយាល័យសហព្រះរាជអាជ្ញា និងមេធាវីការពារទាំងពីរក្រុមបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[៤]។ នួន ជា បានទទួលមរណភាពនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០១៩ ហើយកិច្ចដំណើរការនីតិវិធីចំពោះរូបគាត់ត្រូវបានបញ្ចប់[៥]។ បន្ទាប់ពីបានដាក់សំណើសុំបង្កើនចំនួនទំព័រ និងបន្ថែមពេលវេលា[៦] អង្គជំនុំជម្រះតុលាការកំពូលបានណែនាំ

---

[១] *សូមមើល* ឯកសារ **E1/529.1** ប្រតិចារឹកនៃសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

[២] ឯកសារ **E465** សាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (សាលក្រមដែលមានសំអាងហេតុពេញលេញត្រូវបានជូនដំណឹងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩)។

[៣] ឯកសារ **F43** សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ១៣។

[៤] ឯកសារ **E465/2/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ (ដោយកំណត់នូវមូលដ្ឋានមួយនៃបណ្តឹងសាទុក្ខ)។ ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ (ដោយបង្ហាញនូវកំហុសចំនួន ១.៨២៤ និងសេចក្តីសម្រេចចំនួន ៣៥៥ របស់អង្គជំនុំជម្រះសាលាដំបូង)។ ឯកសារ **E465/3/1** សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ (ដោយកំណត់នូវមូលដ្ឋានចំនួន ៣៥១ នៃបណ្តឹងសាទុក្ខ)។

[៥] ឯកសារ **F46/3** សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០១៩។

[៦] ឯកសារ **F45** សំណើរបស់មេធាវីការពារក្តីលោក ខៀវ សំផន សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩។

ឲ្យ ខៀវ សំផន ដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួននៅត្រឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ជាភាសាអង់គ្លេស ឬភាសាបារាំង (ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន) ហើយថា សារណានោះមិនឲ្យលើសពីចំនួន ៧៥០ ទំព័រទេ[៧]។ អង្គជំនុំជម្រះតុលាការកំពូលបានណែនាំបន្ថែមដល់សហព្រះរាជអាជ្ញាឲ្យដាក់សារណាតបរបស់ខ្លួនតែមួយភាសាសិន មិនឲ្យលើសពីចំនួន ៣៥០ ទំព័រ ក្នុងរយៈពេល ១២០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសារណាបណ្តឹងសាទុក្ខ[៨]។

២. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមប្រកាសអំពីបំណងរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដោយសារសារណានោះប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី[៩]។ ស្របទៅនឹងនីតិវិធីដែលបានអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ សហមេធាវីនាំមុខស្នើសុំដាក់ចម្លើយតបរបស់ខ្លួន បន្ទាប់ពីសហព្រះរាជអាជ្ញាបានចេញចម្លើយតបរបស់ខ្លួនរួច ដើម្បីបញ្ចៀសភាពជាន់គ្នា និងភាពច្រំដែល។ សហមេធាវីនាំមុខស្នើសុំការអនុញ្ញាតដាក់មួយភាសាសិន ក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំណែកសំណៅបកប្រែនឹងដាក់តាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ សហមេធាវីនាំមុខស្នើសុំបង្កើនចំនួនទំព័រ ឲ្យបានដល់ ៣២០ ទំព័រ។

## II. ច្បាប់ជាធរមាន

### ក. សិទ្ធិក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន

---

[៧] ឯកសារ **F49** សំណើសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ ៣៦។

[៨] *ដូចយោងខាងលើ*។

[៩] ឯកសារ **F10/2** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៧ ("សេចក្តីសម្រេចលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី")។

៣. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិក្នុងការឆ្លើយតប ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី៖

> ជាការពិតណាស់ថា "ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក មានឋានៈជាភាគី"។ ដូចដែលបានបញ្ជាក់នៅក្នុងសាលដីកាក្នុងសំណុំរឿង ០០១ ដើមបណ្តឹងរដ្ឋប្បវេណីទទួលបាន "សិទ្ធិចូលរួមយ៉ាងពេញលេញដែលដើមបណ្តឹងរដ្ឋប្បវេណីមានផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ[កម្ពុជា] និងវិធានផ្ទៃក្នុង នៅមុខដំណាក់កាលជំនុំជម្រះ ក្នុងដំណាក់កាលជំនុំជម្រះ និងក្នុងដំណាក់កាលបណ្តឹងសាទុក្ខ"។ តែទោះជាយ៉ាងណាក៏ដោយ គប្បីធ្វើការកត់សម្គាល់ដែលថា ភាគីនីមួយៗមានដូចជា "សហព្រះរាជអាជ្ញា ជនត្រូវចោទ/ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់សិទ្ធិចូលរួមក្នុងនីតិវិធីខុសៗគ្នា ទៅតាមមុខងារ និងការទទួលខុសត្រូវជាក់លាក់របស់ខ្លួន នៅក្នុងកិច្ចដំណើរការនីតិវិធី[១០]។

៤. អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់សំអាងហេតុថា សិទ្ធិក្នុងការឆ្លើយតប៖

> ដរាបណាទឡ្ហីករណ៍នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ មេធាវីការពារក្តី ប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី សិទ្ធិរបស់ខ្លួនក្នុងការជំទាស់ទៅនឹងបណ្តឹងសាទុក្ខនេះកើតចេញយ៉ាងសមហេតុផល ពីបុព្វសិទ្ធិដែលបានផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់កាលស៊ើបអង្កេត ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបណ្តឹងសាទុក្ខ។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា "ភាគី" មានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គជំនុំជម្រះដែលមានសមត្ថកិច្ច រហូតដល់ពេលដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដូចមានចែងយ៉ាងលម្អិតនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ការអនុញ្ញាតឲ្យដាក់បណ្តឹង និងសារណាជាលាយលក្ខណ៍អក្សរ រួមបញ្ចូលយ៉ាងសមហេតុផល នូវសិទ្ធិដាក់សារណាតប និងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់ភាគីមួយទៀត ដែលស្របទៅតាមក្របខណ្ឌនៃកិច្ចដំណើរការនីតិវិធីចំពោះមុខ។ ដូច្នេះ ការមិនទទួលស្គាល់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការឆ្លើយ

[១០] ឯកសារ **F10/2** សេចក្តីសម្រេចលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១១។

តបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី នៅក្នុងដំណាក់កាលនេះ គឺជាការមិនស្របទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងតួនាទីជាទូទៅរបស់ពួកគេ នៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី[១១]។

៥. ទោះបីបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសិទ្ធិឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការកំណត់ព្រំដែនចំនួនពីរចំណុច ដើម្បីរក្សាសមភាពនៃមធ្យោបាយតទល់ក្តីគ្នា និងកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព គឺថា៖ (១) "ទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសារណាតបដែលបានស្នើឡើង ត្រូវតែទាក់ទិនទៅនឹងមូលហេតុនានា ដែលប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី" និង (២) "សហមេធាវីនាំមុខត្រូវតែព្យាយាមបញ្ចៀសនូវភាពច្រំដែល និងភាពជាន់គ្នាទៅលើបញ្ហានានា ដែលមានរួចហើយនៅក្នុងសារណាតប ដែលសហព្រះរាជអាជ្ញាបានគ្រោងរៀបចំឡើង"[១២]។

## ខ. ការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រ

៦. សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ("សេចក្តីណែនាំអនុវត្ត") ផ្តល់រយៈពេល ១០ ថ្ងៃសម្រាប់ការដាក់ចម្លើយតប[១៣]។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា "វិធាន ៣៩(២) នៃវិធានផ្ទៃក្នុងចែងថា លើកលែងតែមានចែងផ្សេងពីនេះ នៅក្នុងវិធានផ្ទៃក្នុង និងស្របតាមសេចក្តីណែនាំអនុវត្ត ចៅក្រមអាចកំណត់ពេលវេលា សម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ។ វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង ក៏បានផ្តល់អំណាចដល់ចៅក្រមមានសិទ្ធិបន្ថែមពេលវេលាដែលចៅក្រមបានកំណត់នោះ"[១៤]។

---

[១១] ឯកសារ F10/2 សេចក្តីសម្រេចលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤។

[១២] ឯកសារ F10/2 សេចក្តីសម្រេចលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៧។

[១៣] មាត្រា ៨.៣ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក/វិ.លើកទី៨ ("សេចក្តីណែនាំអនុវត្ត")។

[១៤] ឯកសារ F43 សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ៧។

៧. ទាក់ទិននឹងកម្រាស់ឯកសារដែលបានដាក់នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល សេចក្តីណែនាំអនុវត្តចែងថា មិនត្រូវលើសពី ៣០ទំព័រជាភាសាអង់គ្លេស ឬបារាំង[១៥] តែអង្គជំនុំជម្រះ "អាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស តាមការស្នើសុំរបស់ភាគីចូលរួម"[១៦]។

## គ. ការដាក់ឯកសារមួយភាសា

៨. មាត្រា ៧.១ នៃសេចក្តីណែនាំអនុវត្តតម្រូវឲ្យដាក់ឯកសារទាំងអស់ជាភាសាខ្មែរ ព្រមទាំងភាសាអង់គ្លេស ឬភាសាបារាំង។ ទោះជាយ៉ាងណាក្តី មាត្រា ៧.២ ចែងថា "នៅក្នុងកាលៈទេសៈពិសេស សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះណាមួយនៃ អ.វ.ត.ក អាចអនុញ្ញាតឲ្យភាគីណាមួយដាក់ឯកសារជាភាសាបារាំង ឬ ភាសាអង់គ្លេសជាបឋមបាន ប៉ុន្តែបន្ទាប់មក ភាគីត្រូវដាក់ឯកសារជាភាសាខ្មែរដែលបានបកប្រែរួច ឲ្យបានឆាប់រហ័សបំផុត"។

៩. អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់បន្ថែមថា "ការអនុញ្ញាតឲ្យដាក់ឯកសារតែមួយភាសាជាភាសាអង់គ្លេស ឬបារាំង បន្ថែមលើការធ្វើយុត្តិកម្មអំពីកាលៈទេសៈពិសេស ចាំបាច់ត្រូវផ្អែកលើការសន្មតថា សមាសភាពជាតិនៅក្នុងអង្គភាពដាក់ឯកសារត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីខ្លឹមសារនៃឯកសារ និងពុំបានទទួលរងការប៉ះពាល់ដល់សិទ្ធិនៅក្នុងការបង្ហាញពីជំហាររបស់ខ្លួនឡើយ"[១៧]។

## III. សារណា

១០. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីយ៉ាងធំធេង នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២។ យ៉ាងហោចណាស់ មួយផ្នែកនៃសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកលើគ្រប់ដើមបណ្តឹងរដ្ឋប្បវេណី

---

[១៥] មាត្រា ៥.២ សេចក្តីណែនាំអនុវត្ត។

[១៦] មាត្រា ៥.៤ សេចក្តីណែនាំអនុវត្ត។

[១៧] ឯកសារ **E463/1/1/1** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាតែមួយភាសា ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៨។

ទាំង ៦៣នាក់ដែលបានមកផ្តល់សក្ខីកម្ម។ ហេតុដូច្នេះហើយ ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាមូលដ្ឋាននៃសំអាងហេតុ និងសំអាងច្បាប់ជាច្រើន ដែលបានរកឃើញនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

១១. សហមេធាវីនាំមុខបានធ្វើការប៉ាន់ស្មានអំពីវិសាលភាពនៃចម្លើយតបរបស់ខ្លួន ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដោយព្យាយាមកំណត់អំពីចំនួនមូលដ្ឋាននៃបណ្តឹងសាទុក្ខដែលអាចប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដំណើរការនេះមានការលំបាក ដោយសារទម្រង់ និងខ្លឹមសារនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។ បណ្តឹងសាទុក្ខរបស់ ខៀវ សំផន មានការលើកឡើងយ៉ាងច្បាស់ថា "មិនគ្រប់ជ្រុងជ្រោយ"[១៨]។ ជាងនេះទៀត ក្រៅពីការពន្យល់ថា សេចក្តីជូនដំណឹងនេះបាន "គូសបញ្ជាក់ដោយសង្ខេបនូវកំហុស" ការពិតកថាខណ្ឌ ១៧ ដល់ ៣៤ មិនបានសំគាល់*កំហុស*ពាក់ព័ន្ធនឹងការធ្វើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវយកមកតវ៉ានោះឡើយ។ ហេតុនេះ ជាការចាំបាច់ដែរសម្រាប់សហមេធាវីនាំមុខត្រូវធ្វើការសន្និដ្ឋាននៅក្នុងវិសាលភាពទូលំទូលាយ ថាតើកំហុសឆ្គងណាខ្លះដែលអាចចោទប្រកាន់បាន ទាក់ទិននឹងសេចក្តីសន្និដ្ឋានទាំងនេះ។

១២. បន្ទាប់ពីបានអនុវត្តដំណើរការនេះ សហមេធាវីនាំមុខបានរកឃើញបញ្ហាអង្គសេចក្តីចំនួនច្រើនជាង ៤០បញ្ហា ពាក់ព័ន្ធនឹងកថាខណ្ឌ ឬសេចក្តីសម្រេចចំនួនច្រើនជាង ១០០ ដែលមានរៀបរាប់នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងឧបសម្ព័ន្ធ របស់ ខៀវ សំផន ដែលទំនងជាប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខបានរកឃើញភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៦ នាក់ដែលត្រូវបានជំទាស់ និងដែលនឹងតម្រូវឱ្យមានការឆ្លើយតបជាក់លាក់មួយម្តងៗ។ ដោយផ្អែកទៅលើរបៀបបង្កើតជាមូលដ្ឋាននៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សហមេធាវីនាំមុខប្រមើលឃើញថា ការជំទាស់ទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ផ្សេងទៀតអាចមានភាពជាន់គ្នាដែលចាំបាច់ត្រូវលើកយកពិភាក្សាក្នុង

[១៨] ឯកសារ **E465/4/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៩ កថាខណ្ឌ ១០ និង ១៥។

លក្ខណៈកាន់តែទូលំទូលាយ ក្នុងក្របខ័ណ្ឌទាក់ទងទៅនឹងបញ្ហាអង្គសេចក្តី។ សហមេធាវីនាំមុខគូសបញ្ជាក់ថា ចំនួនទាំងនេះតំណាងឱ្យការប៉ាន់ស្មានអប្បបរមាជាបឋម ដោយផ្អែកលើវិសាលភាពនៃព័ត៌មានដែលរកបាន នៅក្នុងសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ និងឧបសម្ព័ន្ធរបស់ ខៀវ សំផន។

១៣. សហមេធាវីនាំមុខទទួលស្គាល់នូវភាពចាំបាច់ដើម្បីរក្សាតុល្យភាពនៃសិទ្ធិក្នុងចំណោមភាគីនានាក្នុងអំឡុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ[១៩] និងខិតខំប្រឹងប្រែងបញ្ចៀសនូវភាពច្រំដែលនៅក្នុងសារណាតបរបស់អយ្យការ។ ស្របទៅនឹងការអនុវត្តន៍នៅក្នុងសំណុំរឿង ០០២/០១[២០] សហមេធាវីនាំមុខសូមលើកឡើងថា ការពិនិត្យទៅលើចម្លើយតបរបស់សហព្រះរាជអាជ្ញាមុននឹងដាក់ចម្លើយតបរបស់ខ្លួន គឺជាវិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុតនៃការបញ្ចៀសនូវភាពជាន់គ្នា និងភាពច្រំដែល។ សហមេធាវីនាំមុខស្នើសុំដាក់ចម្លើយតបរបស់ខ្លួនក្នុងរយៈពេលចំនួន ៦០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីចម្លើយតបរបស់សហព្រះរាជអាជ្ញា ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការបញ្ចៀសនូវភាពច្រំដែលនៅក្នុងចម្លើយតបរបស់ខ្លួន។ សហមេធាវីនាំមុខយល់ឃើញថា នៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខទាំងមូល ថិរវេលាចំនួន ៦០ថ្ងៃ នឹងពុំមែនជាការពន្យារពេលហួសហេតុក្នុងការបញ្ចប់ការជំនុំជម្រះឡើយ។ សហមេធាវីនាំមុខសូមគូសបញ្ជាក់ថា ពុំមានបំណងអូសបន្លាយកិច្ចដំណើរការនីតិវិធីឱ្យយូរជាងភាពចាំបាច់ដាច់ខាតនោះឡើយ ដោយហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ជាខ្លាំងដែលចង់ឃើញកិច្ចដំណើរការនីតិវិធីទាំងនេះ ត្រូវបានបញ្ចប់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

១៤. អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឱ្យ ខៀវ សំផន ដាក់សារណាចំនួន ៧៥០ ទំព័រ ហើយសហព្រះរាជអាជ្ញាត្រូវឆ្លើយតបដល់ទៅចំនួន ៣៥០ ទំព័រ។ ដោយសារបញ្ហាមានចំនួនច្រើនលើសលប់ ដែលដើមបណ្តឹងរដ្ឋប្បវេណីមានផលប្រយោជន៍ត្រូវឆ្លើយតបនោះ សហមេធាវីនាំមុខស្នើសុំទំព័រសរុបចំនួន ៣២០ ទំព័រ។ ចំនួននេះផ្អែកទៅលើការគណនា

---

[១៩] ឯកសារ **F10/2** សេចក្តីសម្រេចលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤, ១៧។

[២០] ឯកសារ **F10/2** សេចក្តីសម្រេចលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ២០។

ចេញពីចំនួនបញ្ហា និងចំនួនដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរកឃើញបឋមថាទំនងជាតម្រូវឱ្យធ្វើការឆ្លើយតប[២១]។ សហមេធាវីនាំមុខកត់សម្គាល់ថា ចំនួនសរុបនេះអាចត្រូវបានកាត់បន្ថយ ដោយពិចារណាទៅលើភាពជាន់គ្នាក្នុងចំណោមមូលដ្ឋាន និង/ឬ ចម្លើយតបទៅនឹងមូលដ្ឋានទាំងនោះ ក៏ប៉ុន្តែសហមេធាវីនាំមុខក៏ដឹងដែរថា ចំនួនបញ្ហា និងចំនួនដើមបណ្តឹងរដ្ឋប្បវេណី ដែលបានគណនានៅដំណាក់កាលនេះ ទំនងជាតំណាងឱ្យការប៉ាន់ស្មានបែបអភិរក្ស។

១៥. ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី សហមេធាវីនាំមុខស្នើសុំឆ្លើយតបតែមួយភាសាសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរ នឹងដាក់តាមក្រោយឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ សហមេធាវីនាំមុខសូមលើកឡើងថា ប្រការនេះជាការប្រើប្រាស់ធនធានយ៉ាងមានប្រសិទ្ធភាពបំផុត ដោយពិចារណាថា ចម្លើយតបរបស់ខ្លួននឹងមានការផ្លាស់ប្តូរជាចាំបាច់អាស្រ័យទៅតាមខ្លឹមសារនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា ដែលទឡ្ហីករណ៍មួយចំនួននឹងត្រូវដកចេញ ដោយសារពុំចាំបាច់ ហើយទឡ្ហីករណ៍មួយចំនួនទៀតចាំបាច់ត្រូវដាក់បន្ថែម។ ហេតុនេះ វាជាការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាពថែមទៀត ដែលត្រូវធ្វើការកែសម្រួលទៅលើសំណៅមួយនៃចម្លើយតប ហើយដាក់ទៅបកប្រែសិន ជាជាងធ្វើការកែសម្រួលទៅលើចម្លើយតបជាពីរភាសាតែម្តងនោះ។ សហមេធាវីនាំមុខយល់ឃើញថា ដំណើរការនេះមិនប៉ះពាល់ដល់ភាគីជាតិឡើយ ដោយសារនៅក្នុងអង្គភាពសហមេធាវីនាំមុខនេះត្រូវមានដំណើរការពិគ្រោះយោបល់ក្នុងការតាក់តែងចម្លើយតប និងមានសំណៅសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលមានជាភាសាខ្មែរដែលបានផ្តល់មកក្នុងរយៈពេលដ៏សមរម្យ។

---

[២១] សហមេធាវីនាំមុខប៉ាន់ស្មានថា ចម្លើយតបរបស់ខ្លួននឹងតម្រូវជាមធ្យម ៦ ទំព័រ សម្រាប់បញ្ហាអង្គសេចក្តីមួយ ដោយកត់សម្គាល់ថា បញ្ហាខ្លះអាចត្រូវការច្រើនទំព័រជាងនេះ ហើយបញ្ហាខ្លះអាចត្រូវការតិចទំព័រជាងនេះ ដែលសរុបមានចំនួនប្រហែល ២៤០ ទំព័រសម្រាប់បញ្ហាទាំងនេះ (៦ ទំព័រ គុណនឹងបញ្ហាចំនួន ៤០)។ សហមេធាវីនាំមុខប៉ាន់ស្មានបន្ថែមថា ៤ ទំព័រសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជំទាស់ម្នាក់ (កត់សម្គាល់ផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននឹងត្រូវការច្រើនទំព័រជាងនេះ ឯដើមបណ្តឹងរដ្ឋប្បវេណីខ្លះទៀតត្រូវការតិចទំព័រជាងនេះ) ដែលមានចំនួនប្រហែល ៦៤ ទំព័រ (៤ ទំព័រ គុណនឹងដើមបណ្តឹងរដ្ឋប្បវេណី ១៦ នាក់)។ សហមេធាវីនាំមុខរំពឹងថា ផ្នែកសេចក្តីផ្តើម ផ្នែកនីតិវិធី និង ផ្នែកសេចក្តីសន្និដ្ឋាន អាចលើកឡើងយ៉ាងសមហេតុផល ដោយប្រើប្រាស់ ១៦ ទំព័រ។

## IV. សំណើ

**អាស្រ័យហេតុនេះ** ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

(១) **អនុញ្ញាត**ឱ្យសហមេធាវីនាំមុខដាក់ចម្លើយតបរបស់ខ្លួនទៅនឹង សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងរយៈពេលចំនួន ៦០ ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីចម្លើយតបរបស់សហព្រះរាជអាជ្ញា និង

(២) **ទទួលយក**សំណើរបស់សហមេធាវីនាំមុខ ដែលស្នើសុំបង្កើនចំនួនទំព័រសម្រាប់ចម្លើយតបរបស់ខ្លួនឱ្យបានដល់ ៣២០ ទំព័រ និង

(៣) **ទទួលយក**សំណើរបស់សហមេធាវីនាំមុខ ដែលស្នើសុំដាក់ចម្លើយតបរបស់ខ្លួនជាភាសាអង់គ្លេសសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

សូមលោក-លោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០១៩ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Megan HIRST<br>សហមេធាវីនាំមុខ | ឡុងដ៍ | |